ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

ក្រសួងមហាផ្ទៃ

លេខ :..........

# សេចក្តីជូនដំណឹង
# ស្តីពី
# ការរំលឹកចំពោះ
# សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលខកខានមិនបានបំពេញកាតព្វកិច្ចតាមការកំណត់ដោយច្បាប់

កន្លងមកក្រសួងមហាផ្ទៃ បានធ្វើការជូនដំណឹងតាមរយៈលិខិតចុះថ្ងៃទី០៤ ខែកក្កដា **ឆ្នាំ២០១៧** ដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានចុះបញ្ជី និងតម្កល់សំណុំឯកសារនៅក្រសួងមហាផ្ទៃ ឲ្យបំពេញលក្ខខណ្ឌដែលបានកំណត់ក្នុង **មាត្រា១០** និង**មាត្រា២៥** នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ តាមរយៈការជូនដំណឹងនេះ មានសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចំនួន **៦៤៨ ប៉ុណ្ណោះ** ដែលបានបំពេញកាតព្វកិច្ចត្រឹមត្រូវតាមការកំណត់ដោយច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ ទន្ទឹមនេះ ក៏នៅមានសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មួយចំនួនធំទៀត នៅតែមិនបំពេញកាតព្វកិច្ចតាមបទប្បញ្ញត្តិដែលកំណត់ដោយច្បាប់នៅឡើយ។

ក្រសួងមហាផ្ទៃ **សូមរំលឹកសាជាថ្មី** ចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលខកខានមិនបានបំពេញកាតព្វតាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ នាពេលកន្លងមក ដូចតទៅ៖

**១.** សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលបានចុះបញ្ជី និងតម្កល់សំណុំឯកសារនៅក្រសួងមហាផ្ទៃ ត្រូវបំពេញកាតព្វកិច្ចដូចខាងក្រោម៖

- ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីព័ត៌មានរាល់គណនី ដែលត្រូវបើកសម្រាប់កិច្ចប្រតិបត្តិការរបស់ខ្លួននៅធនាគារ ក្នុងព្រះរាជាណាចក្រកម្ពុជា មកក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាម **មាត្រា១០** នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល **ឲ្យបានមុនដំណាច់ខែកុម្ភៈ ឆ្នាំ២០១៨** ជាកំណត់។

- ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងមហាផ្ទៃ ក្នុងករណីមានការធ្វើវិសោធនកម្មលក្ខន្តិកៈ ឬការផ្លាស់ប្តូរទីស្នាក់ការ ឬការផ្លាស់ប្តូរតំណែងប្រធានឬតំណែងនាយកប្រតិបត្តិ ឬការប្រែប្រួលព័ត៌មានគណនីធនាគារ ដោយភ្ជាប់មកជាមួយនូវសំណុំលិខិតដែលបានផ្លាស់ប្តូរ ឬប្រែប្រួល ក្នុងរយៈពេលយ៉ាងយូរ ១៥(ដប់ប្រាំ)ថ្ងៃ។



ទីស្តីការក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទលេខ (៨៥៥) ២៣៧២៦០៥២ - ២៣៧២៦០៥៣
ទូរសារ (៨៥៥) ២៣៧២៦០៥២ - ២៣៧២៦០៥៣ e-meil: moi@interior.gov.kh web: www.interior.gov.kh

- អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវផ្ញើមកក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមួយច្បាប់ ស្របតាម **មាត្រា២៥** នៃច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មិនឲ្យហួសពី**ដំណាច់ខែកុម្ភៈនៃឆ្នាំបន្ទាប់**។ ក្នុងករណី ដែលទទួលបានការគាំទ្រហិរញ្ញវត្ថុពីម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនោះ ត្រូវផ្ញើរបាយការណ៍ ខាងលើ ដោយចម្លងចេញពីឯកសារដើមដែលផ្ញើទៅម្ចាស់ជំនួយ ក្នុងអំឡុងពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពី ថ្ងៃផ្ញើទៅម្ចាស់ជំនួយ ព្រមទាំងឯកសារគម្រោងកម្មវិធីការងារ និងកិច្ចព្រមព្រៀងហិរញ្ញប្បទាន ១(មួយ)ច្បាប់ ដែលម្ចាស់ជំនួយបានយល់ព្រម ដោយចម្លងពីឯកសារដើម ឲ្យបានក្នុងអំឡុងពេល៣០(សាមសិប)ថ្ងៃ ពីថ្ងៃម្ចាស់ ជំនួយបានឯកភាពយល់ព្រម។ របាយការណ៍នេះត្រូវតម្កល់ទុកនៅទីស្នាក់ការរបស់ខ្លួនរយៈពេលយ៉ាងតិច ៥ (ប្រាំ)ឆ្នាំ។ ចំពោះរបាយការណ៍បូកសរុបសកម្មភាពការងារ និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំ**ឆ្នាំ២០១៦** ត្រូវផ្ញើ មកក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **ឲ្យបានមុនដំណាច់ ខែកុម្ភៈ ឆ្នាំ២០១៨** ជាកំណត់។

**២.** សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាមួយ ខកខានមិនបានបំពេញតាម លក្ខខណ្ឌដូចមានចែងក្នុងចំណុច១ ខាងលើ ក្រសួងមហាផ្ទៃនឹងចាត់វិធានការតាមផ្លូវច្បាប់។

ថ្ងៃ.ចន្ទ ៤ រោច... ខែ.កត្តិក.ឆ្នាំរកា ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី...១៣.... ខែ...១១....... គ.ស ២០១៧

**ក្រសួងមហាផ្ទៃ**